រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
លេខ: ...ឧ.ជ.ប.ត.ញ.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីណែនាំ
ស្តីពី
ការចាត់ទិធានការបន្ការ ឧប់ស្តាត់ការនាំចូល ការជួញដូរ ការធ្វើអាជីវកម្ម និងការប្រើប្រាស់ផលិតផល អេចល៍ ធី អី (HTPs) ក្នុងព្រះរាជាណាចក្រកម្ពុជា

ដោយពិនិត្យឃើញថា ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ផលិតផល អេចល៍ ធី អី (HTPs) បារីអេឡិចត្រូនិក (Electronic Nicotine Delivery System-EDNS) និងអេចល៍ ធី អី (HTPs-Heated Tobacco Products) ជាផលិតផលថ្នាំជក់ថ្មី ដែលត្រូវបានគេផលិតឡើងដើម្បីជំនួសផលិតផលថ្នាំជក់ធម្មតា ជាពិសេសទាក់ទាញឱ្យមានការប្រើប្រាស់ក្នុងចំណោមយុវវ័យ។ បារីអេឡិចត្រូនិក និងអេចល៍ ធី អី ត្រូវបានគេប្រើប្រាស់តាមរយៈឧបករណ៍ម្យ៉ាងដែលប្រើថ្មពិល បង្កើតថាមពេលកំដៅក្នុងការបំលែងអង្គធាតុដែលដាក់ចូលឧបករណ៍នោះឱ្យទៅជាចំហាយ។ ចំពោះ បារីអេឡិចត្រូនិក គេបន្តក់វត្ថុរាវស្អិតដែលមានសារធាតុនីកូទីន និងអង្គធាតុរាវដែលមានក្លិនក្រអូប (ក្លិនផ្លែឈើ ក្លិនផ្តា...) ទៅក្នុងឧបករណ៍ ហើយពេលត្រូវកំដៅដែលបានមកពីថាមពលថ្មពិល អង្គធាតុទាំងនេះនឹងបំលែងជាចំហាយ ដែលអ្នកប្រើប្រាស់អាចហឹត បឹត ឬជក់តាមចិត្តចង់ ដោយឡែក អេចល៍ ធី អី គឺជាសរសៃថ្នាំជក់ និងអង្គធាតុផ្តល់ក្លិនក្រអូប ត្រូវបានគេដាក់ទៅក្នុងឧបករណ៍ជក់ដែលប្រើថាមពលថ្មដូចបារីអេឡិចត្រូនិកដែរ។ ប៉ុន្តែផលិតផល អេចល៍ ធី អី ថ្មីៗ ដែលគេឱ្យឈ្មោះថា ហាយប្រឹដ (Hybrid) គឺគេបានប្រើវត្ថុរាវស្អិត ជំនួសសន្លឹកថ្នាំជក់ ដាក់ចូលទៅក្នុងឧបករណ៍ជក់។ ដូចនេះ បារីអេឡិចត្រូនិក និងអេចល៍ ធី អី វិវឌ្ឍន៍ឆ្ពោះទៅកាន់តែដូចគ្នាក្នុងការប្រើប្រាស់វត្ថុរាវស្អិត និងអង្គធាតុរាវមានក្លិន សម្រាប់បង្កើតជាចំហាយ និងផ្សែង។

ក្នុងពេលកន្លងមកនេះ បារីអេឡិចត្រូនិក និងអេចល៍ ធី អី ត្រូវបានជនខិលខូចផ្សព្វផ្សាយលក់តាមបណ្តាញព័ត៌មានសង្គម ដោយពន្យល់ថាជាឧបករណ៍សម្រាប់ផ្តាច់ការជក់បារី ជាផលិតផលមានសុវត្ថិភាពជាងបារីធម្មតា មិនប៉ះពាល់ដល់បរិស្ថាន។ល។ ដែលសុទ្ធតែផ្ទុយទៅនឹងការអះអាងរបស់អង្គការសុខភាពពិភពលោក (WHO) និងស្ថាប័នសុខភាពធំៗលើសកលលោក ដែលបានកំណត់យ៉ាងច្បាស់ថា ការជក់បារីអេឡិចត្រូនិក និងអេចល៍ ធី អី បណ្តាលឱ្យញៀន កើតជំងឺសួតធ្ងន់ធ្ងរ រហូតដល់បាត់បង់ជីវិត ហើយក៏អាចជាកត្តាលើកទឹកចិត្ត និងជំរុញឱ្យឈានទៅប្រើប្រាស់គ្រឿងញៀនខុសច្បាប់ផ្សេងៗទៀតផងដែរ។ យោងតាមមជ្ឈមណ្ឌលពិនិត្យជំងឺ Centers for Diseases Control (CDC) ការិយាល័យរដ្ឋបាលត្រួតពិនិត្យអាហារ និងថ្នាំញៀន Food and

អគ្គលេខាធិការដ្ឋាននៃអ.ជ.ប.ត.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ. Phone, Fax: (855) 23 721 648, Fax: (855) 23 727 529
P.O.Box: 151 E-mail: info@nacd.gov.kh Website : www.nacd.gov.kh

Scanned with CamScanner

Drug Administration (FDA) របស់សហរដ្ឋអាមេរិក បានបង្ហាញឱ្យដឹងថា អ្នកប្រើប្រាស់បារីអេឡិចត្រូនិក និងអេចឈ៍ ធី ភី ក្នុងចំណោមសិស្សអនុវិទ្យាល័យ (ថ្នាក់ទី៦ ដល់ទី៨) និងសិស្សវិទ្យាល័យ (ថ្នាក់ទី៩ ដល់ទី១២) មានប្រេវ៉ាឡង់ ៤.៧% និង១០.៦% នៅឆ្នាំ២០២០។ ថ្វីត្បិតតែការប្រើប្រាស់នេះ បានថយចុះនៅឆ្នាំ២០២០ ធៀបទៅនឹងឆ្នាំ២០១៩ (សិស្សអនុវិទ្យាល័យមានចំនួន១០.៥% និងសិស្សវិទ្យាល័យមានចំនួន២៧.៥%) ហើយនៅពេលបច្ចុប្បន្ននៅសហរដ្ឋអាមេរិកមានអ្នកប្រើប្រាស់បារីអេឡិចត្រូនិក ក្នុងចំណោមសិស្សានុសិស្សប្រមាណ៣.៦លាននាក់។ បើតាមករណីសិក្សាមួយនៅសហរដ្ឋអាមេរិក ក្នុងចន្លោះពេលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ បានបង្ហាញថា មានជំងឺសួតពាក់ព័ន្ធជាមួយការប្រើប្រាស់បារីអេឡិចត្រូនិចចំនួន២៨០៧ករណី និងមានអ្នកស្លាប់ចំនួន៦៨នាក់។ ជាងនេះទៀត បារីអេឡិចត្រូនិក និងអេចឈ៍ ធី ភី តែងត្រូវបានគេសង្កេតឃើញថាបានប្រើប្រាស់រួមគ្នា ដើម្បីជាការសន្សំថវិកា ឬជាចំណង់ចំណូលចិត្តរបស់យុវជន ដើម្បីបង្ហាញពីភាពរាក់ទាក់ស្និទ្ធស្នាល ដែលឥរិយាបទនៃការប្រើប្រាស់បែបនេះអាចបង្កហានិភ័យយ៉ាងខ្លាំងក្នុងការឆ្លងរីករាលដាលនៃជំងឺឆ្លងផ្សេងៗ ពិសេសជំងឺកូវីដ-១៩ ក្នុងបរិបទថ្មីនេះ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលដែលមានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជាសេនាធិការ បានយកចិត្តទុកដាក់ និងបានរិះរកគ្រប់វិធីសាស្ត្រដើម្បីបង្ការ និងទប់ស្កាត់រាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន ដែលក្នុងនោះរាប់បញ្ចូលទាំងការប្រើប្រាស់បារីអេឡិចត្រូនិកនេះផងដែរ ក្នុងគោលបំណងរួមចំណែកបង្ការ និងទប់ស្កាត់រាល់បញ្ហាដែលមានការប៉ះពាល់ដល់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជាបង្ការនិងទប់ស្កាត់រាល់ផលប៉ះពាល់នានាលើការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងការអភិវឌ្ឍសង្គមជាតិ។ ជាក់ស្តែងក្នុងឆ្នាំ២០១៤ កន្លងទៅ ដោយមានការឯកភាពពីរាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានចេញសេចក្តីណែនាំលេខ០០១/ស.ណ.ន អ.ជ.ប.គ.ញ ស្តីពីការចាត់វិធានការបង្ការ បញ្ឈប់ការប្រើប្រាស់ ការធ្វើអាជីវកម្ម និងការនាំចូលផលិតផលស៊ីហ្សា និងបារីអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើហេតុផលថា ក្រៅពីអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការប្រើប្រាស់បារីអេឡិចត្រូនិក និងផលិតផលស៊ីហ្សា ក៏អាចបង្កលក្ខណៈងាយស្រួល ជំរុញ និងលើកទឹកចិត្តឱ្យមានការប្រើប្រាស់ប្រភេទគ្រឿងញៀនខុសច្បាប់ផងដែរ។ សេចក្តីណែនាំនោះ ត្រូវបានផ្សព្វផ្សាយ និងអនុវត្តយ៉ាងយកចិត្តទុកដាក់ពីសំណាក់សមត្ថកិច្ចអនុវត្តច្បាប់គ្រប់ប្រភេទ និងអាជ្ញាធរមូលដ្ឋាន ដែលធ្វើឱ្យរាល់បញ្ហាត្រូវបានបង្ការ និងទប់ស្កាត់យ៉ាងមានប្រសិទ្ធភាព។ ប៉ុន្តែ ក្នុងពេលកន្លងទៅថ្មីៗនេះ មានព័ត៌មាន ជាច្រើនឱ្យដឹងថាមានបងប្អូនប្រជាពលរដ្ឋ ពិសេសក្រុមយុវជនមួយចំនួនបានប្រើប្រាស់បារីអេឡិកត្រូនិកឡើងវិញ ហើយមួយចំនួនទៀតក៏បាននិងកំពុងសាកល្បងប្រើប្រាស់ អេចឈ៍ ធី ភី ផងដែរ។ បញ្ហានេះអាចបណ្តាលមកពីក្រុមឧក្រិដ្ឋជន ឬជនខិលខូចលួចលាក់នាំចូល និងលក់ដូរ ក្នុងពេលដែលប្រជាជាតិទទួលរងវិបត្តិទឹកជំនន់ទឹកភ្លៀងនាពេលកន្លងទៅថ្មីៗ ក៏ដូចជាវិបត្តិនៃការរីករាលដាលជំងឺកូវីដ-១៩ ដែលបាននិងកំពុងកើតមាននាពេលបច្ចុប្បន្ននេះ។ ដោយសារអេចឈ៍ ធី ភី (HTPs) មិនមានចែងក្នុងសេចក្តីណែនាំលេខ០០១/ស.ណ.ន អ.ជ.ប.គ.ញ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានចេញកាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ នោះ ការបង្ការ ក៏ដូចជាការទប់ស្កាត់ការចរាចរជួញដូរអេចឈ៍ ធី ភី អាចជាការលំបាក។

Scanned with CamScanner

ឆ្លើយតបនឹងបញ្ហាខាងលើ និងដោយមានការអនុញ្ញាត និងការណែនាំពីរាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមធ្វើការណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន សមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ទាំងអស់ដូចខាងក្រោម:

១. បន្ថែមលើការពង្រឹងការអនុវត្តសេចក្តីណែនាំលេខ០០១/ស.ណ.ន អ.ជ.ប.គ.ញ. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការចាត់វិធានការបង្ការ បញ្ឈប់ការប្រើប្រាស់ ការធ្វើអាជីវកម្ម និងការនាំចូលផលិតផលស៊ីហ្សា និងបារីអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់វិធានការជាបន្ទាន់ បញ្ឈប់លែងឱ្យមានការប្រើប្រាស់ និងការធ្វើអាជីវកម្មផលិតផល អេចឈ៍ ធី ភី (HTPs) ក្នុងគ្រប់រូបភាព ដោយត្រូវធ្វើការដកហូត និងរឹបអូសយកផលិតផលទាំងនោះមករក្សាទុក។ ការដកហូត និង រឹបអូសយកផលិតផល អេចឈ៍ ធី ភី (HTPs) មិនត្រូវធ្វើឱ្យប៉ះពាល់ដល់អាជីវកម្មស្របច្បាប់ផ្សេងទៀតជាដាច់ខាត។

២. ត្រូវបញ្ឈប់ និងឃាត់ទុកនូវរាល់ការចរាចរ ការជួញដូរ និងការនាំចូលផលិតផល អេចឈ៍ ធី ភី (HTPs) តាមគ្រប់រូបភាព និងត្រូវធ្វើការផ្សព្វផ្សាយពីការហាមឃាត់មិនឱ្យមានការនាំចូលចំពោះអ្នកធ្វើអាជីវកម្ម និងប្រជាជនទូទៅឱ្យបានទូលំទូលាយ។

៣. គ្រប់ក្រសួង-ស្ថាប័ន សមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើរបាយការណ៍ពីលទ្ធផលនៃការអនុវត្តខ្លឹមសារសេចក្តីណែនាំនេះ មកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដើម្បីធ្វើការបូកសរុបរាយការណ៍ជូនរាជរដ្ឋាភិបាល។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន សមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ត្រូវចាត់ចែងដឹកនាំអនុវត្តតាមខ្លឹមសារ នៃសេចក្តីណែនាំនេះឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ឆ្នាំជូតទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញថ្ងៃទី ១ ខែ [illegible] ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

នាយឧត្តមសេនីយ៍ ង៉ែត គីមយ៉ាន

កន្លែងទទួល
- ឧទ្ធកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់គណៈកម្មាធិការ ត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ

Scanned with CamScanner